ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៣៩២៥ មស. ៧/៦៣

# សេចក្ដីជូនដំណឹង

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងទេសចរណ៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជម្រាបជូនដំណឹងដល់បេក្ខជនទាំងអស់ឱ្យបានជ្រាបថា៖

**ក.** គណៈកម្មការរៀបចំការប្រឡងនឹងធ្វើការបិទផ្សាយសេចក្ដីសម្រេចស្ដីពីការអនុញ្ញាឱ្យបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចូលរួមប្រឡង **ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ** នៅតាមក្រសួង ស្ថាប័ន ដូចមានរៀបរាប់ខាងលើ។

**ខ. សម័យប្រឡង៖** ថ្ងៃអាទិត្យ ទី២៤ ខែតុលា ឆ្នាំ២០២១

**គ. មណ្ឌលប្រឡង៖** គណៈកម្មការរៀបចំការប្រឡងកំណត់ដូចខាងក្រោម៖

១. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ **(RUPP)** ៖ សម្រាប់បេក្ខជនប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**២.វិទ្យាល័យ ជា ស៊ីម សន្ធរម៉ុក និងបឋមសិក្សាសន្ធរម៉ុក** ៖ សម្រាប់បេក្ខជនប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម ក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងទេសចរណ៍។

**៣.វិទ្យាល័យបាក់ទូក** ៖ សម្រាប់បេក្ខជនប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា។

**ឃ. វិញ្ញាសាប្រឡង** ៖ គណៈកម្មការរៀបចំការប្រឡងកំណត់ដូចខាងក្រោម៖

១. បេក្ខជនដែលបានដាក់ពាក្យសុំសិទ្ធប្រឡងចូលបម្រើការងារក្នុងក្របខ័ណ្ឌ ក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល វិញ្ញាសាប្រឡងត្រូវបានកំណត់ដូចខាងក្រោម៖

+ ចំណេះដឹងពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ និងភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ២ម៉ោង ទៅតាមប្រភេទក្របខ័ណ្ឌ។



ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

២. បេក្ខជនដែលបានដាក់ពាក្យសុំសិទ្ធប្រឡងចូលបម្រើការងារក្នុងក្របខ័ណ្ឌ ក្រសួងពាណិជ្ជកម្ម វិញ្ញាសាប្រឡងត្រូវបានកំណត់ដូចខាងក្រោម៖

\+ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម និងភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ២ម៉ោង ទៅតាមប្រភេទក្របខ័ណ្ឌ។

៣. បេក្ខជនដែលបានដាក់ពាក្យសុំសិទ្ធប្រឡងចូលបម្រើការងារក្នុងក្របខ័ណ្ឌ ក្រសួងទេសចរណ៍ វិញ្ញាសាប្រឡងត្រូវបានកំណត់ដូចខាងក្រោម៖

\+ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យទេសចរណ៍ និងភាសាអង់គ្លេស រយៈពេល ២ម៉ោង ទៅតាមប្រភេទក្របខ័ណ្ឌ។

**ខ. ពេលវេលាប្រឡង៖**

១. ម៉ោង ០៦ : ០០នាទី ៖ អនុគណៈកម្មការនានា និងបេក្ខជនត្រូវមកដល់មណ្ឌលប្រឡង

២. ម៉ោង ០៦ : ៤៥នាទី ៖ អនុរក្សហៅឈ្មោះបេក្ខជនចូលបន្ទប់ប្រឡង ត្រួតពិនិត្យវត្តមាន ប្រកាសបទបញ្ញត្តិ និងចែកសន្លឹកកិច្ចការដល់បេក្ខជន

៣. ម៉ោង ០៧ : ៣០នាទី ដល់ម៉ោង ០៩ : ៣០នាទី ៖ អនុវត្តវិញ្ញាសាប្រឡង

**ចៈ. សំណុំឯកសារដែលត្រូវភ្ជាប់មកជាមួយនៅពេលប្រឡង**

១. សលាកប័ត្រឯកត្តជន

២. កាតចាក់វ៉ាក់សាំង ឬលិខិតបញ្ជាក់បានចាក់វ៉ាក់សាំង

៣. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត

**ឆ.** ចំពោះប្លង់មណ្ឌលប្រឡង លេខបន្ទប់ និងលេខតុ របស់បេក្ខជននឹងធ្វើការបិទផ្សាយនៅតាមមណ្ឌលប្រឡងដូចបានរៀបរាប់ខាងលើនៅ ថ្ងៃសៅរ៍ ទី២៣ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៨:០០នាទី។

**បញ្ជាក់ ៖** គណៈកម្មការរៀបចំការប្រឡង មានសិទ្ធិកែប្រែសេចក្ដីជូនដំណឹងនេះ ក្នុងករណីចាំបាច់។

ថ្ងៃចន្ទ ៥ កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០២១

**រដ្ឋលេខាធិការ និងជា**

**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**អេង ប៊ុនថុល**

-ឯកសារ កាលប្បវត្តិ